Australian Government
Department of Health and Aged Care

National Women's Health Advisory Council

# កញ្ចប់ព័ត៌មាន

## ក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ #EndGenderBias survey

ខែកក្កដា ឆ្នាំ 2023



Australian Government
Department of Health and Aged Care

National Women's Health Advisory Council

# កញ្ចប់ព័ត៌មាន

## សេចក្ដីផ្ដើម

ក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ ផ្តល់ជូនរដ្ឋាភិបាលអូស្ត្រាលីនូវដំបូន្មាន និងអនុសាសន៍នានា ដើម្បីកែលម្អលទ្ធផលសុខភាពសម្រាប់ស្ត្រី និងកុមារីនៅក្នុងប្រទេសអូស្ត្រាលី។

តាមរយៈក្រសួងសុខាភិបាល និងការថែទាំមនុស្សចាស់ ក្រុមប្រឹក្សានេះបានចាប់ផ្តើមបើកដំណើរការការស្ទង់មតិ #EndGenderBias ដើម្បីយល់ដឹងឱ្យបានកាន់តែប្រសើរអំពីឧបសគ្គ និងភាពលម្អៀងនានាដែលស្ត្រីប្រឈមនៅក្នុងប្រព័ន្ធសុខាភិបាលរបស់ប្រទេសអូស្ត្រាលី។ ការស្ទង់មតិតាមអនឡាញនេះគឺបើកសម្រាប់៖

- ស្ត្រីពេញវ័យ និងអ្នកផ្តល់ការថែទាំស្ត្រី និងកុមារីដែលមានភាពលម្អៀងយ៉េនឌ័រផ្ទាល់ខ្លួននៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី
- អ្នកជំនាញនានាដូចជាអ្នកសិក្សា និងអ្នកជំនាញសុខភាពដែលអាចចែករំលែកទស្សនៈវិស័យរបស់ពួកគេលើឧបសគ្គនានា និងភាពលម្អៀងដែលស្ត្រី និងកុមារីជួបប្រទះក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី។

ទស្សនៈនៃពលរដ្ឋអាទិភាពដូចខាងក្រោម ត្រូវបានស្វែងរកជាក់លាក់៖

- ស្ត្រីដែលជាប្រជាជាតិដំបូង
- ស្ត្រីដែលប្រតិព័ទ្ធស្ត្រីដូចគ្នា មនុស្សខ្ទើយ មនុស្សកែភេទ មនុស្សអន្តរភេទ និងមនុស្សរួមប្រតិព័ទ្ធនឹងមនុស្សដែលមានភេទដូចគ្នា
- មនុស្សដែលមានភាពចម្រុះខាងវប្បធម៌ និងភាសា
- មនុស្សមកពីគ្រួសារដែលមានសេដ្ឋកិច្ច-សង្គមទាប
- មនុស្សមកពីសហគមន៍នៅតាមតំបន់ និងទីដាច់ស្រយាលនានា
- មនុស្សដែលមានបទពិសោធន៍ឆ្លងកាត់ក្នុងជីវិតដែលមានពិការភាព។

ការឆ្លើយតបនានាអាចនៅតែអនាមិក ហើយត្រូវបានដាក់ស្នើតាមអនឡាញតាមរយៈសារជាអត្ថបទ វីដេអូ ឬការថតជាសំឡេង។

ការស្ទង់មតិនេះត្រូវបានគេរំពឹងថានឹងបើកពីថ្ងៃទី 19 ខែកក្កដា ឆ្នាំ 2023 ដល់ថ្ងៃទី 13 ខែតុលា ឆ្នាំ 2023 ហើយអាចចូលបាននៅទីនេះ។

## របៀបប្រើប្រាស់កញ្ចប់នេះ

សមាជិកក្រុមប្រឹក្សា បណ្តាអង្គការភាគីពាក់ព័ន្ធ ក្រុមអ្នកប្រើប្រាស់ ស្ថាប័នសិក្សា និងស្ថាប័នវេជ្ជសាស្ត្រ និងស្ថាប័វិជ្ជាជីវៈ ត្រូវបានអញ្ជើញឱ្យចែករំលែកព័ត៌មាន និងលើកទឹកចិត្តដល់ការចូលរួមក្នុងការស្ទង់មតិជាសកម្មដោយ៖

- ការបោះពុម្ពផ្សាយសារបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយ (សូមមើលមាតិកាខាងក្រោម)
- ការរួមបញ្ចូលអត្ថបទនៅក្នុងព្រឹត្តិប័ត្រព័ត៌មាន និង/ឬនៅលើគេហទំព័ររបស់យើង (សូមមើលឧទាហរណ៍មាតិកាខាងក្រោម)
- ការតាំងបង្ហាញផន ធាននានាដូចជាផ្ទាំងផ្សព្វផ្សាយ (សូមមើលឧទាហរណ៍ខាងក្រោម)
- ការណែនាំដល់ភាគីពាក់ព័ន្ធទៅគេហទំព័រ health.gov.au/womens-health-advisory-council ដើម្បីស្វែងយល់បន្ថែម។

Australian Government
Department of Health and Aged Care

National Women's Health Advisory Council

**ព័ត៌មានបន្ថែម**

សម្រាប់ចម្ងល់នានាទាក់ទងនឹងធនធាននៅក្នុងកញ្ចប់នេះ សូមទាក់ទង campaigns@health.gov.au។

# អត្ថបទព្រឹត្តិប័ត្រព័ត៌មាន

អត្ថបទខាងក្រោមអាចត្រូវបានកែសម្រួល និងបោះពុម្ពផ្សាយនៅលើគេហទំព័រ និង/ឬព្រឹត្តិប័ត្រព័ត៌មានរបស់អ្នក។

## *បញ្ចេញមតិរបស់អ្នកនៅតាម #EndGenderBias នៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី*

ក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ ត្រូវបានបង្កើតឡើងនៅដើមឆ្នាំនេះដើម្បីផ្តល់ដំបូន្មានដល់រដ្ឋាភិបាលអូស្ត្រាលីលើវិធីនានាដើម្បីកែលម្អលទ្ធផលសុខភាពសម្រាប់ស្ត្រី និងកុមារី។ ឥឡូវនេះពួកគេកំពុងអំពាវនាវដល់ស្ត្រី កុមារី និងមនុស្សដែលចាត់ទុកថាស្រីនៅពេលកើត ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេនៅក្នុងការស្ទង់មតិមួយ #EndGenderBias។ ជំនាញ និងមតិកែលម្អពីបណ្តាអ្នកជំនាញថែទាំសុខភាព និងអ្នកជំនាញក៏ត្រូវបានស្វែងរកផងដែរ។។

ដឹកនាំការប្រជុំដោយជំនួយការរដ្ឋមន្ត្រីនៃក្រសួងសុខាភិបាល និងការថែទាំមនុស្សចាស់ សមាជិកសភា Hon Ged Kearney, ក្រុមប្រឹក្សានេះនាំមកជាមួយនូវអ្នកជំនាញការសុខភាពស្ត្រីល្បីៗបំផុតរបស់ប្រទេស ព្រមជាមួយនឹងអ្នកតំណាងមកពីភាពចម្រុះនៃបណ្តាអង្គការភាគីពាក់ព័ន្ធជាន់ខ្ពស់ ក្រុមអ្នកប្រើប្រាស់ និងស្ថាប័នវេជ្ជសាស្ត្រ និងស្ថាប័នជំនាញនានា រួមមានសំឡេងស្ត្រីដែលមានបទពិសោធន៍ឆ្លងកាត់ក្នុងជីវិត។

មានបញ្ហាប្រឈមពិសេសនានាដែលស្ត្រី និងកុមារីប្រឈមនៅក្នុងប្រព័ន្ធសុខាភិបាលរបស់ប្រទេសអូស្ត្រាលីដែលនាំទៅរកលទ្ធផលសុខភាពកាន់តែអន់ខ្សោយ - ចាប់តាំងពីការធ្វើរោគវិនិច្ឆ័យយឺតយ៉ាវ ការផ្តល់វេជ្ជបញ្ជាច្រើនលើសលប់ ការបដិសេធការឈឺចាប់ និងជាច្រើនទៀត។

ជំនួយការរដ្ឋមន្ត្រីឈ្មោះ Kearney មានប្រសាសន៍ថា *"នៅក្នុងប្រទេសអូស្ត្រាលីគ្មានអ្នកណាម្នាក់មិនគួរត្រូវបានគេព្រងើយកន្តើយនោះទេ នៅពេលនិយាយអំពីការថែទាំសុខភាពដែលមានសុវត្ថិភាព មាន គុណភាពខ្ពស់ និងមានតម្លៃសមរម្យ "*។

*"វាមិនអាចទទួលយកបានទាំងស្រុងឡើយដែលក្មេងស្រីម្នាក់រងទុក្ខនូវរោគសញ្ញា ADHD ដែលគ្មានរោគវិនិច្ឆ័យអស់រយៈពេលច្រើនឆ្នាំ ដែលកើតមានឡើងយូរជាងកុមារាម្នាក់ដែលមានអាយុដូចនាង។ ឬស្ត្រីម្នាក់មានការឈឺចាប់ត្រគាកធ្ងន់ធ្ងរម្តងហើយម្តងទៀតត្រូវបានគេបដិសេធ ដែលក្រោយមកត្រូវបានគេរកឃើញថាមានជំងឺមហារីកស្បូនចាប់ពីក្នាសក្នុងស្បូនធ្ងន់ធ្ងរ។"*

ក្រុមប្រឹក្សាមានការចាប់អារម្មណ៍ជាពិសេសក្នុងការស្តាប់ឮពីទស្សនៈនានារបស់ពលរដ្ឋអាទិភាព រួមមានស្ត្រីមកពីប្រជាជាតិដំបូង (First Nations), បណ្តាសហគមន៍ដែលមានភាពចម្រុះខាងវប្បធម៌ និងភាសា ស្ត្រីដែលប្រតិព័ទ្ធស្ត្រីដូចគ្នា មនុស្សខ្ទើយ មនុស្សកែភេទ មនុស្សអន្តរភេទ និងមនុស្សរួមប្រតិព័ទ្ធនឹងមនុស្សដែលមានភេទដូចគ្នា មនុស្សដែលមកពីបណ្តាសហគមន៍នៅតាមតំបន់ និងទីដាច់ស្រយាលនានា ព្រមទាំងមនុស្សដែលមានបទពិសោធន៍ឆ្លងកាត់ក្នុងជីវិតដែលមានពិការភាព។

**បំពេញ (ឬចែករំលែក) ការស្ទង់មតិនៅថ្ងៃនេះ៖**

Australian Government
Department of Health and Aged Care

National Women's Health Advisory Council

ប្រសិនបើអ្នក (ឬអ្នកណាម្នាក់ដែលអ្នកថែទាំ) បានជួបប្រទះនឹងឧសបគ្គក្នុងការចូលប្រើប្រាស់ ឬភាពលម្អៀងយេនឌ័រក្នុងនាមជាស្ត្រីនៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី អ្នកត្រូវបានអញ្ជើញឱ្យចែករំលែកបទពិសោធន៍របស់អ្នក និងបំពេញការស្ទង់មតិឱ្យបានត្រឹមថ្ងៃទី 13 ខែតុលា ឆ្នាំ 2023 ដើម្បីជួយ #EndGenderBias។

ចូលមើលនៅតាមគេហទំព័រ [health.gov.au/womens-health-advisory-council](health.gov.au/womens-health-advisory-council) ដើម្បីទទួលបានការស្ទង់មតិ និងស្វែងយល់បន្ថែមអំពីក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ។

Australian Government
Department of Health and Aged Care

National Women's Health Advisory Council

# សារបង្ហោះសង្គម

ចំណងជើងសារបង្ហោះ និងចំណងជើងរូបភាពខាងក្រោមអាចត្រូវបានបោះពុម្ពផ្សាយនៅលើបណ្តាញសង្គមដែលពេញចិត្តរបស់អ្នក។

| **សារបង្ហោះ** | **រូបភាព** |
|---|---|
| **សម្រាប់សហគមន៍៖**<br>តើអ្នកធ្លាប់មានបញ្ហាជាមួយនឹងគុណភាពនៃការថែទាំសុខភាពដោយព្រោះតែភេទ (យ៉េនឌ័រ) របស់អ្នកទេ? ក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិចង់ឮពីអ្នក។<br>ចែករំលែកបទពិសោធន៍របស់អ្នក ដោយបំពេញការស្ទង់មតិនេះនៅថ្ងៃនេះ៖<br>health.gov.au/womens-health-advisory-council<br>#WomensHealthMatters #EndGenderBias #GenderHealthEquity #EmpowerHerHealth #WithWomenForWomen |  |
| តើអ្នក ឬអ្នកណាម្នាក់ដែលអ្នកថែទាំបានត្រូវគេប្រព្រឹត្តិដោយអយុត្តិធម៌ក្នុងនាមជាស្ត្រីម្នាក់នៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលីទេ?<br>ធ្វើជាផ្នែកនៃដំណោះស្រាយ ហើយបំពេញការស្ទង់មតិ #EndGenderBias មកពីក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ។ ស្វែងយល់បន្ថែម៖<br>health.gov.au/womens-health-advisory-council<br>#WomensHealthMatters #EndGenderBias #GenderHealthEquity #EmpowerHerHealth #WithWomenForWomen |  |
| **សម្រាប់ឧស្សាហកម្ម៖**<br>ក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិចង់ឮពី អ្នកសិក្សា និងអ្នកវិជ្ជាជីវៈសុខភាពនានាដែលអាចចែករំលែកទស្សនៈវិស័យរបស់ពួកគេលើឧបសគ្គ និងភាពលម្អៀងដែលស្ត្រី និងកុមារីជួបប្រទះនៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី។<br>ចែករំលែកបទពិសោធន៍របស់អ្នកដោយបំពេញការស្ទង់មតិ #EndGenderBias នៅថ្ងៃនេះ៖<br>health.gov.au/womens-health-advisory-council<br>#WomensHealthMatters #EndGenderBias #GenderHealthEquity #EmpowerHerHealth #WithWomenForWomen |  |

| | |
|---|---|
| តើអ្នក ឬអ្នកណាម្នាក់ដែលអ្នកថែទាំត្រូវបានគេប្រព្រឹត្តិដោយអយុត្តិធម៌ក្នុងនាមជាស្ត្រីម្នាក់នៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលីទេ?<br>ធ្វើជាផ្នែកនៃដំណោះស្រាយ ហើយបំពេញការស្ទង់មតិ #EndGenderBias មកពីក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ។ ស្វែងយល់បន្ថែម៖<br>[health.gov.au/womens-health-advisory-council](https://health.gov.au/womens-health-advisory-council)<br><br>#WomensHealthMatters #EndGenderBias #GenderHealthEquity #EmpowerHerHealth #WithWomenForWomen |  |
| ក្នុងនាមជាស្ត្រីវ័យក្មេងម្នាក់នៅក្នុងប្រទេសអូស្ត្រាលី តើអ្នកមានអារម្មណ៍ថាភេទ (យ៉េនឌ័រ) របស់អ្នកបាននាំឱ្យមានការលំបាកក្នុងការទទួលបានការថែទាំសុខភាពទេ?<br>ធ្វើជាផ្នែកនៃដំណោះស្រាយ ហើយបំពេញការស្ទង់មតិ #EndGenderBias មកពីក្រុមប្រឹក្សាផ្តល់ដំបូន្មានសុខភាពស្ត្រីថ្នាក់ជាតិ។ ស្វែងយល់បន្ថែម៖<br>[health.gov.au/womens-health-advisory-council](https://health.gov.au/womens-health-advisory-council)<br><br>#WomensHealthMatters #EndGenderBias #GenderHealthEquity #EmpowerHerHealth #WithWomenForWomen |  |

# សារបង្ហោះ

[ទាញយក](#) បោះពុម្ព និងតាំងបង្ហាញផ្ទាំងផ្សព្វផ្សាយនេះនៅលើផ្ទាំងជូនដំណឹង នៅតាមកន្លែងទទួលភ្ញៀវ ឬតំបន់នានាដែលអ្នកផ្តល់ការថែទាំស្ត្រីពេញវ័យ និងកុមារី ដែលមានបទពិសោធន៍ឆ្លងកាត់ក្នុងជីវិតដែលមានភាពលម្អៀងខាងយេ៉ឌ័រនៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី នឹងមើលឃើញវា។

